ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.៨៦១.....សហវ.ប្រក

# ប្រកាស
## ស្តីពី
## ថ្លៃសេវា និងកម្រៃជើងសារវិជ្ជាជីវៈសម្រាប់ការផ្តល់សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើវិសោធនកម្មនៃច្បាប់ ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០០៧
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : ៨៥៥-២៣-៤៣០ ២២៥ ទូរសារ : ៨៥៥-២៣-៤៣០ ៧៩៩
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA. Phone : 855-23-430 225 / Fax : 855-23-430 799

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៦៤៣ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៧ ស្ដីពីកាតព្វកិច្ចដាក់របាយការណ៍ ហិរញ្ញវត្ថុឱ្យធ្វើសវនកម្មគណនេយ្យសហគ្រាស
- បានឃើញប្រកាសលេខ ១៣៣០ សហវ.ប្រក ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់នាយកដ្ឋានក្រោមចំណុះអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ៦៣៦ សហវ.ប្រក ចុះថ្ងៃទី ២៩ខែ មិថុនា ឆ្នាំ ២០១៧ ស្ដីពីការគ្រប់គ្រងអាជីវកម្មផ្ដល់សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងដូចខាងក្រោម÷

- ធានាប្រសិទ្ធភាពនៃការគ្រប់គ្រង និងត្រួតពិនិត្យលើការយកកម្រៃសេវា និងកម្រៃជើងសារិជ្ជាជីវៈសម្រាប់ ការផ្ដល់សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ
- ធានាសមធម៌ និងតុល្យភាពនៃផលប្រយោជន៍រវាងក្រុមហ៊ុន និងអតិថិជនដែលប្រើប្រាស់សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ
- រក្សាបានសណ្ដាប់ធ្នាប់នៅក្នុងទីផ្សារអចលនវត្ថុ តាមរយៈការជំរុញឱ្យមានការប្រកួតប្រជែងដោយសមភាព តម្លាភាព និងយុត្តិធម៌នៅក្នុងទីផ្សារអចលនវត្ថុ។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅកំណត់ អំពីមូលដ្ឋាននៃការកំណត់ថ្លៃសេវា និងកម្រៃជើងសារិជ្ជាជីវៈសម្រាប់ការផ្ដល់សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាពពាក់ព័ន្ធការយកថ្លៃសេវា និងកម្រៃជើងសារិជ្ជាជីវៈសម្រាប់ការផ្ដល់សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.-**

និយមន័យនៃបច្ចេកសព្ទដែលមានចែងក្នុងប្រកាសនេះ ត្រូវបានកំណត់ដូចខាងក្រោម÷

- **ក្រសួង** សំដៅដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- **ក្រុមប្រឹក្សានីតិកម្ម** សំដៅដល់ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **អគ្គនាយកដ្ឋាន** សំដៅដល់អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **នាយកដ្ឋាន** សំដៅដល់នាយកដ្ឋានគ្រប់គ្រងអាជីវកម្មអចលនវត្ថុ បញ្ចាំ និងប្រាតិភោគដោយអនុប្បទាន នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- **ទ្រព្យ** សំដៅដល់ពាក្យបច្ចេកសព្ទរួម ដើម្បីសម្គាល់នូវប្រភេទថ្នាក់នៃទ្រព្យសកម្ម មួយចំនួនដូចជា: អចលនវត្ថុទ្រព្យសកម្មរូបិយ ទ្រព្យសកម្មអរូបិយ ធុរកិច្ច និងអត្ថប្រយោជន៍ផ្សេងដែលតាំងនៅ ឬភ្ជាប់ទៅនឹងធុរកិច្ច
- **ទ្រព្យពិសេស** សំដៅដល់ទ្រព្យរោងចក្របរិក្ខា អចលនវត្ថុឯកទេសកម្ម ធុរកិច្ច និងអត្ថប្រយោជន៍ផ្សេងដែលតាំងនៅ ឬភ្ជាប់ទៅនឹងធុរកិច្ច
- **ទ្រព្យរោងចក្របរិក្ខា** សំដៅដល់ទ្រព្យសកម្មរូបិយមួយប្រភេទដែលកាន់កាប់ដោយអង្គភាពមួយ សម្រាប់ប្រើនៅក្នុងផលិតកម្ម ឬការផ្គត់ផ្គង់ទំនិញ ឬសេវាកម្ម ឬសម្រាប់បំពេញមុខងារជួល។ ទ្រព្យរោងចក្របរិក្ខា រួមមាន ការតម្លើង និងបំពាក់ដោយគ្រឿងម៉ាស៊ីន និងបរិក្ខានានាយ៉ាងពេញលេញ សម្រាប់បម្រើឱ្យដំណើរការឧស្សាហកម្ម ឬពាណិជ្ជកម្ម និង/ឬខ្សែចង្វាក់ផលិតកម្ម រួមទាំងការបំពាក់គ្រឿងសង្ហារិម គ្រឿងតុបតែងលំអ និងគ្រឿងបំពាក់ផ្សេងៗដែលតាំងនៅជាប់នឹងអាគារ
- **អចលនវត្ថុឯកទេសកម្ម** សំដៅដល់អចលនវត្ថុមួយប្រភេទ ដែលមានលក្ខណៈកម្រ និងមានលក្ខណៈពិសេសពីធម្មជាតិតែមួយគត់ដែលតម្រូវឱ្យការរៀបចំ និងការស្ថាបនាឡើងនូវទម្រង់សំណង់ ឬអគារ ដើម្បីឱ្យស្របទៅនឹងលក្ខណៈពិសេសរបស់វា រួមទាំងការកំណត់ទំហំ ទីតាំង និងការបំពាក់បរិក្ខា និងគ្រឿងបង្គុំផ្សេងៗ។ អចលនវត្ថុទាំងនោះ រួមមាន: រោងចក្រចម្រាញ់ប្រេងកាត និងកន្លែងផលិតសារធាតុគីមី រោងចក្រថាមពលអគ្គិសនី រោងចក្រផលិត និងតម្លើងនាវា គ្រឿងបង្គុំឯកទេសសម្រាប់ផលិតកម្ម ទីធ្លាសាធារណៈរបស់រដ្ឋ ព្រះវិហារ និងសារមន្ទីរ។ល។
- **គោលបំណងពិសេស** សំដៅដល់កម្មវត្ថុនៃការវាយតម្លៃដែលផ្តោតលើគោលបំណងណាមួយជាកំណត់ ដូចជា÷ ពន្ធ តុលាការ ឬវេទិកាមជ្ឈត្តកម្ម ការដាក់ជូនគណៈកម្មការមូលបត្រកម្ពុជាសម្រាប់សំណើបោះផ្សាយមូលបត្រជាសាធារណៈ ធានារ៉ាប់រងអគ្គីភ័យ និងគោលបំណងទាំងឡាយពាក់ព័ន្ធការវាយតម្លៃធុរកិច្ច និងអត្ថប្រយោជន៍ផ្សេងៗដែលតាំងនៅ ឬភ្ជាប់ទៅនឹងធុរកិច្ច
- **អប្បហារ** សំដៅដល់ការបញ្ចុះថ្លៃ។

## ជំពូកទី ២
## មូលដ្ឋានកំណត់ថ្លៃសេវា និងកម្រៃជើងសាវិជ្ជាជីវៈ

**ប្រការ៥.-**

ថ្លៃសេវា និងកម្រៃជើងសាវិជ្ជាជីវៈ ដែលក្រុមហ៊ុនត្រូវទទួលបានពីអតិថិជន ត្រូវបានកំណត់ខាងក្រោម÷

| ល.រ | ១. សម្រាប់ក្រុមហ៊ុនវាយតម្លៃ | | |
|---|---|---|---|
| ១. | ប្រតិបត្តិការ | តម្លៃ (គិតជាដុល្លារ) | ថ្លៃសេវាវិជ្ជាជីវៈ |
| ១.១ | ១. ការវាយតម្លៃអចលនវត្ថុ | ក្រោម ១០០.០០០ | ០,១៧% ឬអប្បបរមា ១៧០ ដុល្លារ |
| | | ១០០.០០១- ១.០០០.០០០ | ០,១០% |
| | | ១.០០០.០០១-៥.០០០.០០០ | ០,០៥០% |
| | | ៥.០០០.០០១-១០.០០០.០០០ | ០,០៣០% |
| | | លើសពី ១០.០០០.០០១ | ០,០២៥% |
| ១.២ | ២. ការវាយតម្លៃអចលនវត្ថុគោលបំណងពិសេស ឬទ្រព្យពិសេស | មិនកំណត់តម្លៃ | ថ្លៃសេវាវិជ្ជាជីវៈត្រូវគណនាតាមករណីនីមួយៗដោយមានការព្រមព្រៀងជាមុនពីអតិថិជន។ |
| ១.៣ | ៣. បច្ចុប្បន្នកម្មនៃការវាយតម្លៃទៅលើ ទ្រព្យដែល ដូចមានក្នុងប្រភេទៈ (១) និង(២)។ | មិនកំណត់តម្លៃ | គិតក្នុងអត្រា៥០% នៃថ្លៃសេវាវិជ្ជាជីវៈ ដែលទទួលបានពីការវាយតម្លៃកាលពីលើកមុន |
| ២ | ២. សម្រាប់ក្រុមហ៊ុនភ្នាក់ងារអចលនវត្ថុ និងក្រុមហ៊ុនគ្រប់គ្រងអចលនវត្ថុ÷ | | |
| | ប្រតិបត្តិការ | រយៈពេល (ឆ្នាំ) | កម្រៃសេវាវិជ្ជាជីវៈ |
| ២.១ | ១. ទិញ លក់អចលនវត្ថុ | មិនកំណត់ | អប្បបរមា៣% |
| ២.២ | ២. ជួល | រយៈពេលក្រោម ០១ឆ្នាំ | តាមការព្រមព្រៀងរបស់ភាគី |
| | | ០១ឆ្នាំ | ថ្លៃឈ្នួលអចលនវត្ថុ ០១ខែ |
| | | លើសពី ០១ឆ្នាំ | ថ្លៃឈ្នួលអចលនវត្ថុ ០១ខែ និងបូកបន្ថែមចំនួន ២៥%ទៅតាមសមាមាត្រនៃការជួលតាមឆ្នាំនីមួយៗ |
| ២.៣ | ៣. ប្រតិបត្តិការគ្រប់គ្រងអចលនវត្ថុ | មិនកំណត់ | តាមការព្រមព្រៀងរបស់ភាគី |

**ប្រការ៦.-**

រូបមន្តនៃការគណនាមូលដ្ឋានកំណត់ថ្លៃសេវា និងកម្រៃជើងសារិជ្ជាជីវៈ សម្រាប់ការបំពេញប្រតិបត្តិការសេវាកម្មនីមួយៗដូចមានចែងប្រការ៥ ខាងលើ ត្រូវបានកំណត់ក្នុងតារាង ដូចបានជូនភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ជំពូកទី ៣**

**ការកំណត់ថ្លៃសេវា និងកម្រៃជើងសារិជ្ជាជីវៈ**

**ប្រការ៧.-**

ត្រូវបានចាត់ទុកជាបច្ចុប្បន្នកម្មនៃការវាយតម្លៃលើទ្រព្យដដែល ចំពោះការធ្វើបច្ចុប្បន្នកម្មលើការវាយតម្លៃដោយក្រុមហ៊ុនវាយតម្លៃតែមួយលើទ្រព្យ ដែលជាកម្មវត្ថុនៃការវាយតម្លៃម្តងហើយក្នុងរយៈពេលតិចជាង ឬស្មើ ០២ (ពីរ)ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការវាយតម្លៃចុងក្រោយ។ ដោយឡែក ទ្រព្យដែលធ្លាប់ជាកម្មវត្ថុនៃការវាយតម្លៃ លើសពី ០២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការវាយតម្លៃចុងក្រោយពុំអាចក្លាយជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នកម្ម នៃការវាយតម្លៃលើទ្រព្យដដែលបានឡើយ គឺត្រូវតែក្លាយជាកម្មវត្ថុនៃការវាយតម្លៃឡើងវិញ។

**ប្រការ៨.-**

ក្រុមហ៊ុនភ្នាក់ងារអចលនវត្ថុ អាចធ្វើអប្បហារកម្រៃជើងសារិជ្ជាជីវៈសម្រាប់ការធ្វើប្រតិបត្តិការលក់-ទិញអចលនវត្ថុជូនអតិថិជន។ អត្រាអប្បហារនៃកម្រៃជើងសារិជ្ជាជីវៈ មិនត្រូវធ្វើលើសពី ៥០% (ហាសិបភាគរយ) នៃកម្រៃជើងសារិជ្ជាជីវៈដែលបានកំណត់ក្នុងប្រការ៥ នៃប្រកាសនេះ។

**ប្រការ៩.-**

ក្រុមហ៊ុន ត្រូវបង្ហាញតារាងថ្លៃសេវា និង/ឬកម្រៃជើងសារិជ្ជាជីវៈ ព្រមទាំងអនុវត្តការយកថ្លៃសេវា និងកម្រៃជើងសារិជ្ជាជីវៈ ដូចមានកំណត់ក្នុងប្រការ៥ នៃប្រកាសនេះ ដោយពន្យល់ឱ្យបានច្បាស់លាស់អំពីរូបមន្តនៃការគណនាថ្លៃសេវា និង/ឬកម្រៃជើងសារិជ្ជាជីវៈនៃប្រភេទសេវាកម្មនីមួយៗ មុនពេលផ្តល់សេវាកម្មជូនអតិថិជន។

**ប្រការ១០.-**

ក្រុមហ៊ុន មិនត្រូវកំណត់ថ្លៃសេវា និង/ឬកម្រៃជើងសារិជ្ជាជីវៈជាថ្នូនឹងការបំពេញសេវាកម្មជូនអតិថិជនរបស់ខ្លួន ដែលផ្ទុយនឹងថ្លៃសេវា និង/ឬកម្រៃជើងសារិជ្ជាជីវៈដូចមានកំណត់ក្នុងប្រការ៥ នៃប្រកាសនេះឡើយ។

ក្រុមហ៊ុន អាចទទួលថ្លៃសេវា ឬកម្រៃជើងសា ប្រាក់រង្វាន់ អំណោយ លាភសក្ការៈ ការលើកទឹកចិត្ត ឬអត្ថប្រយោជន៍ផ្សេងៗបន្ថែមដោយផ្ទាល់ ឬប្រយោលពីបុគ្គល ឬភាគីដទៃទៀត ពាក់ព័ន្ធនឹងការបំពេញសេវាកម្មរបស់ខ្លួនលុះត្រាតែបានជូនដំណឹង និងទទួលបានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីអតិថិជន។

**ប្រការ១១.-**

ក្រុមហ៊ុន ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ និងទទួលបានការយល់ព្រមជាមុនពីអតិថិជន ក្នុងករណីការបំពេញសេវាកម្មរបស់ខ្លួន តម្រូវឱ្យមានចំណាយផ្សេងៗទៀតកើតឡើងបន្ថែមលើការយកថ្លៃសេវា ឬកម្រៃជើងសារិជ្ជាជីវៈ។

**ប្រការ១២.-**

ក្រុមហ៊ុន ត្រូវបិទផ្សាយ និងផ្សព្វផ្សាយអំពីតារាងថ្លៃសេវា និងកម្រៃជើងសារវិជ្ជាជីវៈដែលត្រូវយកពីអតិថិជនសម្រាប់ការបំពេញសេវាកម្មទៅតាមប្រភេទសេវាកម្មនីមួយៗដូចមានចែងក្នុងប្រការ ៥ នៃប្រកាសនេះជាសាធារណៈ។

## **ជំពូកទី ៤**

## **ទោសប្បញ្ញត្តិ**

**ប្រការ១៣.-**

ក្រុមហ៊ុន ឬបុគ្គលទាំងឡាយណាដែលប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិដូចមានចែងក្នុងប្រកាសនេះ នឹងត្រូវបានស៊ើបអង្កេតដោយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួង។

ក្នុងករណីរកឃើញថា ក្រុមហ៊ុន ឬបុគ្គលណាប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិដូចមានចែងក្នុងប្រកាសនេះ ក្រសួង នឹងចាត់វិធានការទណ្ឌកម្មរដ្ឋបាល និង/ឬពិន័យអន្តរការណ៍ដូចមានចែងក្នុងប្រកាសលេខ ៦៣៦ ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៧ ស្តីពីការគ្រប់គ្រងអាជីវកម្មផ្តល់សេវាកម្មវាយតម្លៃ និងសេវាកម្មអចលនវត្ថុ និងបទប្បញ្ញត្តិគតិយុត្តជាធរមាន។

## **ជំពូកទី ៥**

## **អវសានប្បញ្ញត្តិ**

**ប្រការ១៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៥.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមហ៊ុន និងរូបវន្តបុគ្គលដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង/ស្ថាប័ន
- ធនាគារជាតិនៃកម្ពុជា
- សាលារាជធានី ខេត្ត
- ដូចប្រការ១៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ